# សាលារៀនជំនាន់ថ្មី



## ការជួយយុវជនឲ្យត្រៀមលក្ខណៈសម្រាប់សតវត្សទី២១

## ការលើកកម្ពស់គុណភាពនៃយុវភាព

សាលារៀនជំនាន់ថ្មីនីមួយៗនឹងត្រូវអង្កេត និងវាយតម្លៃដោយក្រុមប្រឹក្សាភិបាលដែលនឹងធ្វើឱ្យការបំពេញភារកិច្ចប្រកបដោយស្តង់ដារខ្ពស់។

# ទិដ្ឋភាពទូទៅ

កម្មវិធីសាលារៀនជំនាន់ថ្មីគឺជាសមាសភាគដ៏សំខាន់មួយនៃកម្មវិធីកំណែទម្រង់វិស័យអប់រំដែលបានគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីនឹងបង្កើតលំនាំមួយដែលនឹងនាំឱ្យមានការបង្កើតសាលារៀនរដ្ឋស្វយ័ត ដែលនឹងទទួលបានការវិនិយោគពិសេសភ្ជាប់ទៅនឹងស្តង់ដារថ្មីមួយនៃគណនេយ្យភាព និងអភិបាលកិច្ចសាលារៀន។ សាលាដែលមិនឆ្លើយតបនឹងស្តង់ដារជាសាលារៀនជំនាន់ថ្មី នឹងបាត់បង់ឋានៈជាសាលារៀនជំនាន់ថ្មី ហើយសាលារៀននឹងនេះនៅតែដើរតាមកម្មវិធីក្រសួងដែលមានការវិនិយោគធម្មតាលើវិស័យអប់រំ។ សាលារៀនជំនាន់ថ្មីនឹងផ្តល់ស្តង់ដារអប់រំថ្មីមួយនៅក្នុងសាលារដ្ឋដើម្បីរៀបចំយុវជនកម្ពុជាសម្រាប់សតវត្សទី២១។

កម្មវិធីនេះនឹងចាប់ផ្តើមនៅវិទ្យាល័យ **ព្រះស៊ីសុវត្ថិ** រាជធានីភ្នំពេញ និងពង្រីកនៅបណ្តាខេត្តបន្តបន្ទាប់។ គម្រោងនេះផ្តល់មូនិធិដោយផ្ទាល់ពី**ក្រសួងអប់រំ យុវជន និងកីឡា** ដោយសហការប្រតិបត្តិដោយ **អង្គការសម្ពាពសម្រាប់បឋមសិក្សានៅកម្ពុជា "ខេប"**។



# សាលារៀនជំនាន់ថ្មី



# វិធីសាស្ត្រ

កម្មវិធីសាលារៀនជំនាន់ថ្មីនឹងផ្តោតលើការបង្រៀនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាផ្នែកសំខាន់។ ជំនាញទាំងនេះគឺជាជំនាញដែលយុវជនកម្ពុជាត្រូវការចាំបាច់នៅពេលកម្ពុជាបានចូលសមាហរណកម្មអាស៊ាន។ ដូច្នេះសាលារៀនជំនាន់ថ្មីនឹងបន្ថែមម៉ោងបង្រៀនសម្រាប់មុខវិជ្ជាដូចខាងក្រោម៖ គីមីវិទ្យា រូបវិទ្យា ជីវៈវិទ្យា និងព័ត៌មានវិទ្យាបច្ចេកវិទ្យា។

កម្មវិធីនឹងទទួលបានការវិនិយោគពិសេសដើម្បីធ្វើទំនើបកម្មសម្ភារៈសិក្សានៅសាលារៀននេះ រួមមាន៖ ការជួសជុលបន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ ទំនើបកម្មថ្នាក់រៀន បណ្ណាល័យសតវត្សទី២១ និងការិយាល័យប្រឹក្សាដល់សិស្សានុសិស្ស។

# ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន




គ្រូទាំងអស់នឹងត្រូវបានជ្រើសរើសដោយការប្រកួតប្រជែងដើម្បីធានាថា មានតែគ្រូល្អៗតែប៉ុណ្ណោះអាចបង្រៀននៅសាលា  រៀនេះបាន។ គ្រូទាំងអស់នឹងត្រូវជួយក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈខ្ពស់  រួមមានការហាមបង្រៀនគ្នា។ គ្រូ និងគណៈគ្រប់គ្រងដែលបានជ្រើសរើសនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ នឹងចូលរួមក្នុងកម្មវិធីបំប៉នសមត្ថភាព ដែលនឹងចាប់ផ្តើមពីវគ្គបំប៉នមូលដ្ឋាន និងវគ្គបំប៉នបន្តបន្ទាប់ពេញមួយឆ្នាំ និងសិក្ខាសាលាឆ្លុះបញ្ចាំងពិសេស។ គណៈគ្រប់គ្រងសាលានឹងទទួលបានការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ ការធ្វើផែនការ គោលការណ៍នៃការពង្រឹងសិទ្ធិអំណាចយុវជន និងការអនុវត្តតាមគោលការណ៍តឹងរឹងរបស់ក្រសួងដើម្បីកែលម្អអភិបាលកិច្ចល្អសាលារៀន។

**ទំនាក់ទំនង**

**វិទ្យាល័យព្រះស៊ីសុវត្ថិ**

មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរសព្ទលេខៈ ០១២ ៧៦២ ៦៣២/ ០១២ ៧៦៤ ៤៣៩

គេហទំព័រៈ **www.kapekh.org** ទំព័របណ្តាញសង្គមៈ

**www.facebook.com/kapeaction or .../ngsaction**





# សាលារៀនសម្រាប់អ្នកជំនាន់ថ្មី ...

## សេវាពង្រឹងសិទ្ធិអំណាចយុវជន

គោលការណ៍នៃការពង្រឹងសិទ្ធិអំណាចយុវជន គឺស្របតាមគោលនយោបាយអភិវឌ្ឍយុវជនកម្ពុជារបស់ក្រសួងអប់រំ យុវជន និងកីឡា នឹងដើរតួនាទីសំខាន់ក្នុងសាលារៀនជំនាន់ថ្មី។ គោលការណ៍ពង្រឹងសិទ្ធិអំណាចយុវជននឹងបង្ហាញជាក់ស្តែងដោយជម្រើសរបស់សិស្សក្នុងការជ្រើសរើសមុខវិជ្ជាដែលពួកគេចូលចិត្ត ការចូលរួមស្ម័គ្រចិត្តក្នុងក្លឹបសិក្សា និងការផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាកុមារ/យុវជនដែលនឹងជួយគ្រប់គ្រងកម្មវិធី។ សេវាប្រឹក្សាអាជីពដែលផ្តល់ដល់យុវជននឹងជួយគេដើម្បីធានាថា ការសម្រេចចិត្តរបស់គេត្រឹមត្រូវតាមចំណង់ចំណូលចិត្ត និងមានព័ត៌មានគ្រប់គ្រាន់។

## សេវាកម្មពិសេសដល់សិស្ស

សាលារៀនជំនាន់ថ្មី  នឹងផ្តល់នូវសេវាកម្មថ្មីមួយដែលមិនធ្លាប់មានក្នុងសាលារៀនរដ្ឋធម្មតា រួមមានៈ

*បណ្ណាល័យអេឡិចត្រូនិចសតវត្សទី២១ សេវាប្រឹក្សា ក្លឹបមុខវិជ្ជា ការអប់រំបំណិនជីវិត  ការវាយតម្លៃ និងរៀនតាមកម្មវិធីកុំព្យូទ័រ និងអេឡិចត្រូនិច។*